# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីរឿងកូនចៀមនិងឆ្កែចចកក្នុងគតិលោក ប្រៀបមកសង្គមមនុស្សអ្នកធំជិះជាន់អ្នកតូច

Website: www.hoksavann.org

ថ្ងៃទី១៩ ធ្នូ ២០០៤

រឿងក្នុងគតិលោកជារឿងបង្ហាញនូវសកម្មភាពល្អអាក្រក់របស់សង្គមមនុស្ស ដែលអ្នកសិក្សាអានយល់បានមួយភាគក្នុងបញ្ហាសង្គមមនុស្ស ទោះបីរឿងខ្លះយកសត្វធ្វើជាតួអង្គក៏ដោយ ដូចជារឿងកូនចៀមនិងឆ្កែចចក ដែលអ្នកនិពន្ធមានបំណងបង្ហាញនូវអ្នកតូចទន់ខ្សោយត្រូវអ្នកធំមានឥទ្ធិពលធ្វើបាប ទោះបីអ្នកតូចនោះស្លូតបូតត្រឹមត្រូវយ៉ាងណាក៏ដោយ ។ មានដំណើររឿងដោយសេចក្ដីសង្ខេបដូចតទៅនេះ ។ មានកូនចៀមមួយចុះទៅផឹកទឹកក្នុងស្រះមួយ ស្របពេលនោះឆ្កែចចកមួយក៏ចុះទៅដែរ ។ ឆ្កែចចកឃើញកូនចៀមនោះហើយ ចង់ស្ទុះទៅចាប់ស៊ីភ្លាម តែឆ្កែចចកនោះគិតថា បើអញចាប់ស៊ីតែម្ដងក៏បាន ប៉ុន្តែដូចជាពុំអស្ចារ្យ ចាំចាប់កំហុសវាសិន ។ គិតហើយឆ្កែចចកក៏កំហែងទៅកូនចៀមថា វ៉ឺយ អាកូនសត្វតូចនេះ ម្ដេចក៏ឯងប្រហើនម្ល៉េះ មកចុះក្នុងទឹកធ្វើឲ្យទឹកល្អក់អស់ រកតែអញផឹកផងពុំបាន ។ កូនចៀមឮឆ្កែចចកស្ដីចាប់ទោសដូច្នេះក៏ភ័យញ័រ ប៉ុន្តែខំប្រឹងប្រែងប្រមូលសេចក្ដីក្លាហាន ដើម្បីការពារជីវិតតាមគតិយុត្តិធម៌ថា លោកម្ចាស់ ខ្ញុំបាទផឹកទឹកនៅពីក្រោមលោកទេ ទឹកពុំដែលហូរច្រាសទៅខាងលើវិញឡើយ តាមពិតលោកនៅខាងលើខ្ញុំបាទ ។ ឆ្កែចចកទាល់ប្រាជ្ញាទើបយកល្បិចមួយទៀតមកចាប់ទោសដោយចោទថា អើពីឆ្នាំទៅ អាឯងដើរនិយាយដើមអញ ៗរកតែមុខទេតើ ។ កូនចៀមឆ្លើយថា បាទលោកពីឆ្នាំទៅ រូបខ្ញុំបាទនេះមិនទាន់កើតផង បើកើតសោត ក៏នៅពុំទាន់ចេះនិយាយទេ ហេតុដូចម្ដេចបានជាលោកចោទខ្ញុំបាទថានិយាយដើមលោកពីឆ្នាំទៅ ។ ឆ្កែចចកទាល់ប្រាជ្ញាទៀត ទើបយកល្បិចមួយទៀតចោទថា បើអាឯងមិននិយាយព្រោះនៅតូច បើដូច្នេះគឺបងអាឯងនិយាយដើមអញ ។ កូនចៀមឆ្លើយថា ខ្លួនខ្ញុំបាទនេះកើតជាកូនដំបូងក្នុងឧទរនៃមេខ្ញុំបាទ ខ្ញុំបាទគ្មានបងទេ ។ ឆ្កែចចកបន្តចោទទៀតថា បើបងអាឯងគ្មាន បើដូច្នេះមានតែជីដូនជីតាម៉ែឪអាឯងនិយាយដើមអញ ។ កូនចៀមឮឆ្កែចចកចោទនូវពាក្យមានទម្ងន់ងាប់ក្រឡាដូច្នេះ ក៏នៅស្ងៀមពុំអាចឆ្លើយបាន ព្រោះអ្នកណាក៏មានជីដូនជីតាឪពុកម្ដាយដែរ ។ ឆ្កែចចកលុះឃើញកូនចៀមនៅស្ងៀមឆ្លើយពុំរួច ហើយក៏ស្ទុះទៅខាំស៊ីក្នុងពេលនោះទៅ ។

ទាញយករឿងនេះមកឆលុះបញ្ចាំងមើលសង្គមមនុស្ស គឺឆ្កែចចកប្រៀបមកអ្នកមានអំណាច ឯកូនចៀមប្រៀបមកអ្នកទន់ខ្សោយគ្មានអំណាច ។ រឿងនេះមានន័យសេចក្ដីថា អ្នកធំអ្នកមានអំណាចតែងតែរំលោភទៅលើអ្នកតូចតាចជានិច្ច បើអ្នកធំអ្នកមានអំណាចនោះគ្មានធម៌ក្នុងខ្លួន គ្មានមេត្តា គ្មានការគោរពសិទ្ធិមនុស្សទេ ។ ឯអ្នកតូចចាំតែទទួលគ្រោះថ្នាក់ពីអ្នកធំជានិច្ច ទោះបីអ្នកតូចជាអ្នកស្លូតត្រង់គ្មានកំហុសអ្វីក៏ដោយ ។ ការចោទរបស់ឆ្កែចចកទៅលើកូនចៀម គ្រាន់តែជាឆាកកំប្លែងកែអផ្សុករបស់ឆ្កែចចកប៉ុណ្ណោះ បើវាមិនចោទក៏វាអាចទៅខាំស៊ីបាន ហើយបើទោះបីកូនចៀមឆ្លើយរួចទាំងអស់ ដែលធ្វើឲ្យឆ្កែចចកទាល់ប្រាជ្ញាក៏ឆ្កែចចកនៅតែស៊ីកូនចៀមដដែល ។ កូនចៀមដឹងខ្លួនជាមុនថា ខ្លួនពិតជាពុំអាចរួចពីកណ្ដាប់ដៃឆ្កែចចកស៊ីឡើយ ប៉ុន្តែត្រូវតែតស៊ូឆ្លើយមុននឹងបាត់បង់ជីវិត ។ រឿងមួយទៀត តាមរយៈពាក្យចោទរបស់ឆ្កែចចកថាជីដូនជីតាម្ដាយឪពុកជេរ គឺកំហុសរបស់ជីដូនជីតាឪពុកម្ដាយ ត្រូវមានទោសដល់កូន គឺជាច្បាប់ព្រៃផ្សៃជាទីបំផុត ។ រឿងនេះយើងនឹកគួរឲ្យរន្ធត់នូវអំពើឃោរឃៅរបស់មេឃាតករខ្មែរក្រហម ដែលសម្លាប់ខ្មែរទាំងគ្រួសារ បើមានសមាជិកគ្រួសារណាម្នាក់ធ្វើខុស សូម្បីកូនតូចមិនទាន់ដឹងក្ដីក៏ត្រូវរងគ្រោះស្លាប់ដែរ ។ បានជាមានពាក្យខ្មែរមួយឃ្លាពោលថា យុត្តិធម៌នៅលើអ្នកធំអ្នកមានអំណាច ឯអ្នកតូចចាំតែទទួលកំហុសជានិច្ច ។ មនុស្សរបៀបឆ្កែចចកនេះនៅតែមាននៅឡើយក្នុងសង្គមមនុស្ស ចំពោះប្រទេសដែលចុះខ្សោយខាងសីលធម៌និងការគោរពសិទ្ធិមនុស្ស ។ ល្បិចមនុស្សដែលគ្មានសីលធម៌មានវិធីច្រើនយ៉ាង ដើម្បីបំផ្លាញជីវិតនិងសេចក្ដីសុខរបស់អ្នកដទៃ ។ ជួនកាលគេបំផ្លាញជីវិតអ្នកដទៃដោយសម្ងាត់។ ជួនកាលគេបង្កើតលេសដោយខ្លួនគេ ហើយចោទកំហុសនេះទៅលើអ្នកណាដែលខ្លួនគេចង់ព្យាបាទ ។ ដូចឆ្កែចចកចោទកំហុសទៅលើកូនចៀមដែលគ្មានកំហុស ។ អំពើខ្លះគេបង្កើតឲ្យស្របតាមបំណងរបស់អ្នកដែលគេចង់ព្យាបាទដោយបំភ័ន្តឲ្យចូលសំងគេ ដើម្បីមើលជំហរអ្នកណាដែលប្រឆាំងនឹងគេ ។ ល្បិចកិច្ចកលរបស់មនុស្សក្នុងលោកមានច្រើនយ៉ាង បើមិនបានពិនិត្យពិចារណាឲ្យបានម៉ត់ចត់ទេអាចភ័ន្តច្រឡំ ។ ជួនកាលគេជួលមនុស្សពីរបីនាក់ឲ្យធ្វើជាសាក្សីមួលបង្កាច់អ្នកណាម្នាក់ដែលគេចង់កំចាត់ ។ ជួនកាលគេប្រើធម៌ព្រៃ ជួនកាលគេប្រើផ្លូវច្បាប់ ប៉ុន្តែជាច្បាប់ដែលគេបានរៀបចំទុកជាមុន ហើយអ្នកដែលអារកាត់ច្បាប់សុទ្ធតែជាមនុស្សដូចឆ្កែចចកដែលបានសាងបាបកម្មទៅលើអ្នកស្លូតត្រង់នឹងត្រូវវិនាសខ្លួនឯងវិញក្នុងទីអវសាន្ត ។៚